# និយ័តករគណនេយ្យនិងសវនកម្ម

## សៀវភៅណែនាំស្តីអំពីការប្រើប្រាស់

# ប្រព័ន្ធគ្រប់គ្រងការស្នើសុំអាជ្ញាបណ្ណ
# ប្រកបវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម
# តាមអនឡាញ ( E-License System )




@២០២៦ - រក្សាសិទ្ធិគ្រប់យ៉ាងដោយនិយ័តករគណនេយ្យនិងសវនកម្ម

ជំនាន់ ២.០.០

# មាតិកា

អក្សរកាត់..................................................................................................................២
១. សេចក្តីផ្តើម ........................................................................................................... ៣
២. គោលបំណង ............................................................................................................. ៤
៣. អំពីប្រព័ន្ធ ................................................................................................................ ៥
៣.១. ទិដ្ឋភាពរួម........................................................................................................... ៦
៣.២.នីតិវិធីនៃការអនុវត្ត ................................................................................................ ៧
៣.២.១.នីតិវិធីស្នើសុំអាជ្ញាបណ្ណសម្រាប់រូបវន្តបុគ្គល ...................................................... ៧
៣.២.២.នីតិវិធីស្នើសុំអាជ្ញាបណ្ណសម្រាប់នីតិបុគ្គល ........................................................ ៧
៤. លំហូរការងារ និងរបៀបនៃការអនុវត្ត........................................................................... ៨
៤.១. ការបង្កើតគណនីប្រើប្រាស់ជាមួយ CamDigiKey ...................................................... ៩
៤.២. ការចូលប្រើប្រាស់ប្រព័ន្ធជាមួយ CamDigiKey App.................................................. ១១
៤.៣.ការស្នើសុំអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម ..................................... ១៤
៤.៣.១.ការស្នើសុំអាជ្ញាបណ្ណសម្រាប់រូបវន្តបុគ្គល ........................................................... ១៥
៤.៣.២.ការស្នើសុំអាជ្ញាបណ្ណសម្រាប់នីតិបុគ្គល ............................................................ ២២
៤.៣.៣.ការបង់កម្រៃអាជ្ញាបណ្ណប្រចាំឆ្នាំ........................................................................ ២៨
៤.៣.៤.ការបន្តសុពលភាពអាជ្ញាបណ្ណ ............................................................................. ៣០
៥. ផ្នែកទំនាក់ទំនង......................................................................................................៣១

# អក្សរកាត់

| ល.រ | អក្សរកាត់ | អក្សរពេញ |
|---|---|---|
| ១ | ន.គ.ស. | និយ័តករគណនេយ្យនិងសវនកម្ម |
| ២ | E-License System | ប្រព័ន្ធគ្រប់គ្រងការស្នើសុំអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម តាមអនឡាញ |
| ៣ | ICT | Information and Communication Technology |

# ១. សេចក្តីផ្តើម



សេដ្ឋកិច្ចឌីជីថល គឺជាសេដ្ឋកិច្ចដែលពឹងផ្អែកលើការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្នុងការភ្ជាប់ទំនាក់ទំនងគ្នារវាងមនុស្ស អាជីវកម្ម ឧបករណ៍ ទិន្នន័យ និងដំណើរការនានា។ រាជរដ្ឋាភិបាលកម្ពុជា មានបំណងប្រាថ្នាប្រែក្លាយសេដ្ឋកិច្ចតាមបែបប្រពៃណីឱ្យទៅជាសេដ្ឋកិច្ចតាមបែបឌីជីថលនាពេលអនាគត។ ដើម្បីសម្រេចបាននូវចក្ខុវិស័យនេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវកម្មវិធីកំណែទម្រង់ចាំបាច់នានា ក្នុងនោះក៏មានផ្នែកបច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ *(ICT)* ផងដែរ។

នៅក្នុងបរិការណ៍នៃការរីករាលដាលនៃជំងឺកូវីដ-១៩ *(COVID-19)* ដែលបង្កឱ្យមានផលប៉ះពាល់ ជាអវិជ្ជមានដល់សេដ្ឋកិច្ច និងសង្គមនៅលើសកលលោក រួមទាំងព្រះរាជាណាចក្រកម្ពុជាផងដែរ។ វិធានការនៃការដោះស្រាយវិបត្តិចំពោះមុខតាមរយៈការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ *(ICT)* គឺពិតជាមិនអាចខ្វះបាន ក្នុងការជួយធានាប្រក្រតីភាពនៃកិច្ចការងាររបស់ស្ថាប័នរដ្ឋ និងឯកជន ដែលជាផ្នែកមួយនៃចន្ទល់សេដ្ឋកិច្ចរបស់ប្រទេស។ និយ័តករគណនេយ្យ និងសវនកម្ម ដែលជាសេនាធិការតែមួយគត់របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការគ្រប់គ្រងវិស័យ និងវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម ក្រោមការចង្អុលបង្ហាញផ្ទាល់ពី**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ** បានអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ក្នុងការផ្តល់សេវាសាធារណៈនានា និងបានដាក់ឱ្យអនុវត្តជាបន្តបន្ទាប់ រួមទាំងប្រព័ន្ធគ្រប់គ្រងការស្នើសុំ អាជ្ញាបណ្ណ ប្រកបវិជ្ជាជីវៈគណនេយ្យនិងសវនកម្មតាមអនឡាញ ( *E-license System* ) នេះផងដែរ។

# ២. គោលបំណង



ប្រព័ន្ធគ្រប់គ្រងការស្នើសុំអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យនិងសវនកម្មតាមអនឡាញ (*E-license System*) ត្រូវបានបង្កើតឡើង ក្នុងគោលបំណងដើម្បីជួយសម្រួលដល់កិច្ចដំណើរការនៃការប្រើប្រាស់ គ្រប់គ្រង ផ្ទៀងផ្ទាត់ ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ប្រព័ន្ធនេះនឹងរួមចំណែកកាត់បន្ថយចំណាយ និងពេលវេលាក្នុងការបំពេញកាតព្វកិច្ចនានាចំពោះរដ្ឋ បង្កើនតម្លាភាពជានាការគ្រប់គ្រងសហគ្រាសដែលប្រកបវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម ព្រមទាំងគុណភាពនៃការផ្តល់សេវាសាធារណៈ។

# ៣. អំពីប្រព័ន្ធ




## ទិដ្ឋភាពរួម



## នីតិវិធីនៃការអនុវត្ត



# ៣.១. ទិដ្ឋភាពរួម




រូបភាពទី១៖ ទិដ្ឋភាពរួម

# ៣.២. នីតិវិធីនៃការអនុវត្ត

## ៣.២.១.នីតិវិធីស្នើសុំអាជ្ញាបណ្ណសម្រាប់រូបវន្តបុគ្គល




## ៣.២.២.នីតិវិធីស្នើសុំអាជ្ញាបណ្ណសម្រាប់នីតិបុគ្គល



# ៤. លំហូរការងារ និងរបៀបនៃការអនុវត្ត



## ១
### ការបង្កើតគណនីប្រើប្រាស់ ជាមួយ CamDigiKey App




## ២
### ការចូលប្រើប្រាស់ប្រព័ន្ធ ជាមួយ CamDigiKey App



## ៣
### ការស្នើសុំអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម



## ៤.១. ការបង្កើតគណនីប្រើប្រាស់ជាមួយ CamDigiKey

លោកអ្នកអាចបង្កើតគណនីនៅលើកម្មវិធីទូរស័ព្ទដៃ CamDigiKeyបានដោយអនុវត្តតាមជំហានដូចខាងក្រោម៖

❖ **ជំហានទី១៖** ស្វែងរកកន្លែងដែលមានសេវាទូរស័ព្ទនិងប្រព័ន្ធអ៊ីនធឺណេតគ្រប់គ្រាន់




❖ **ជំហានទី២៖** ដោនឡូតកម្មវិធីទូរស័ព្ទដៃ CamDigiKey ពី App Store ឬ Google Play។




❖ **ជំហានទី៣៖** ចូលទៅកាន់កម្មវិធីទូរស័ព្ទដៃ CamDigiKey រួចចុចប៊ូតុង “ចុះឈ្មោះ”។ បន្ទាប់មកចុច បញ្ចូលលេខទូរស័ព្ទដៃ និងអ៊ីម៉ែលនៅក្នុងកម្មវិធីទូរសព្ទ័ដៃ ហើយបញ្ចូលលេខកូដ OTP ដែលបាន ផ្ញើទៅកាន់ទូរស័ព្ទ និងអ៊ីម៉ែលរបស់លោកអ្នក។ បន្តទៀតត្រូវ បញ្ចូលលេខកូដសម្ងាត់ ៦ ខ្ទង់ ផ្ទាល់ខ្លួនរបស់លោកអ្នក រួចចុចប៊ូតុង “បន្ទាប់”។



❖ **ជំហានទី៤៖** ចុចប៊ូតុង “ខ្ញុំត្រូវការប្រើប្រាស់ Face ID” ប្រសិនបើអ្នកត្រូវការ Face ID។ បន្ទាប់មក ស្កេនមុខរស់រវើក របស់លោកអ្នក ដោយចុចប៊ូតុង “ចុចឱ្យជាប់ដើម្បីកត់ត្រា” តាមការណែនាំរបស់កម្មវិធី។



❖ **ជំហានទី៥៖** ស្កេនអត្តសញ្ញាណប័ណ្ណខ្មែរ (សម្រាប់សញ្ជាតិខ្មែរ) និងលិខិតឆ្លងដែន (សម្រាប់សញ្ជាតិបរទេស) ហើយព័ត៌មាននឹងត្រូវបានទាញយកមកដោយស្វ័យប្រវត្តិ រួចចុច "បន្ទាប់"។ បន្ទាប់មក ត្រូវផ្ទៀងផ្ទាត់ ព័ត៌មានឡើងវិញម្តងទៀត ហើយចុចលើប្រអប់ធានាអះអាងព័ត៌មានដែលបានបញ្ចូល និងឯកសារ ដែលបានផ្តល់ជូន គឺជាព័ត៌មានពិតប្រាកដ និងត្រឹមត្រូវ រួចចុច "បន្ទាប់"។



❖ **ជំហានទី៦៖** រង់ចាំការឆ្លើយតបក្នុងរយៈពេល ៨ម៉ោង នៃម៉ោងធ្វើការ។




## ៤.២. ការចូលប្រើប្រាស់ប្រព័ន្ធជាមួយ CamDigiKey App

បន្ទាប់ពីបង្កើតគណនី CamDigiKey រួច លោកអ្នកអាចចូលប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការស្នើសុំអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម តាមអនឡាញ (E-License System) តាមជំហានដូចខាងក្រោម៖

❖ **ជំហានទី១៖** ចូលទៅកាន់គេហទំព័ររបស់ ន.គ.ស. តាមរយៈតំណភ្ជាប់ www.acar.gov.kh រួចជ្រើសរើសយក ប្រព័ន្ធគ្រប់គ្រងការស្នើសុំអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម ដូចរូបខាងក្រោម៖



❖ **ជំហានទី២៖** ចុចប៊ូតុង "ចូលប្រើប្រាស់ប្រព័ន្ធ" ដូចរូបខាងក្រោម៖




❖ **ជំហានទី៣៖** ស្កេន QR ដែលមាននៅលើគេហទំព័រជាមួយកម្មវិធីទូរស័ព្ទដៃ CamDigiKey ដោយចុច "ស្កេន QR Code" លើកម្មវិធីទូរស័ព្ទដៃនោះ បន្ទាប់មក លោកអ្នកអាចប្រើប្រាស់ Fingerprint, Face ID ឬវាយបញ្ចូលលេខកូដ ៦ ខ្ទង់ដែលលោកអ្នកបានបង្កើត។



❖ **ជំហានទី៤៖** បន្ទាប់ពីលោកអ្នកស្កេន QR Code រួច ប្រព័ន្ធនឹងបង្ហាញទំព័រដើមដូចខាងក្រោម ដែលមានមុខងារ៖

១.ស្នើសុំអាជ្ញាបណ្ណ

២.បន្តសុពលភាពអាជ្ញាបណ្ណ

៣.ដាក់បញ្ជូនរបាយការណ៍



## ៤.៣.ការស្នើសុំអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម

ប្រភេទអាជ្ញាបណ្ណត្រូវបានបែងចែកជា ២ប្រភេទធំៗគឺ រូបវន្តបុគ្គល និងនីតិបុគ្គល ដូចដែលបានបង្ហាញដូចរូបខាងក្រោម៖




## ៤.៣.១.ការស្នើសុំអាជ្ញាបណ្ណសម្រាប់រូបវន្តបុគ្គល

លោកអ្នកអាចស្នើសុំអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម សម្រាប់រូបវន្តបុគ្គល មានជា ២ប្រភេទ ទី១ គឺសម្រាប់ជនជាតិខ្មែរ និងទី២ សម្រាប់ជនបរទេស ដោយអនុវត្តតាមជំហានដូចខាងក្រោម៖

### សម្រាប់ជនជាតិខ្មែរ



# សម្រាប់ជនបរទេស




## ៤.៣.១.១.ការស្នើសុំអាជ្ញាបណ្ណសម្រាប់រូបវន្តបុគ្គល ជនជាតិខ្មែរ

លោកអ្នកអាចស្នើសុំអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម សម្រាប់រូបវន្តបុគ្គល ជនជាតិខ្មែរ ដោយអនុវត្តតាមជំហានដូចខាងក្រោម៖

❖ **ជំហានដំបូង៖** សូមចុចលើអាជ្ញាបណ្ណ "រូបវន្តបុគ្គល" បន្ទាប់មកជ្រើសរើសប្រភេទអាជ្ញាបណ្ណដែលលោកអ្នកចង់ស្នើសុំដូចរូបខាងក្រោម



❖ **ជំហានទី១៖** នៅត្រង់ "ជំហានទី១ សូមបញ្ចូលព័ត៌មានផ្ទាល់ខ្លួន រូបថត កម្រិតសិក្សានិងបទពិសោធន៍ការងាររបស់លោកអ្នក រួចចុចប៊ូតុង "រក្សាទុក និងទៅជំហានបន្ទាប់"។ ករណីលោកអ្នកមិនទាន់បំពេញរួចរាល់ លោកអ្នក អាចចុចប៊ូតុង "រក្សាទុកបណ្តោះអាសន្ន" បាន។



❖ **ជំហានទី២៖** នៅត្រង់ "ជំហានទី២ សូមបញ្ចូលឯកសារភ្ជាប់ ដោយចុចប៊ូតុង "បញ្ចូលឯកសារ..." រួចចុច "រក្សាទុក និងទៅជំហានបន្ទាប់"។




❖ **ជំហានទី៣៖** នៅត្រង់ "ជំហានទី៣ សូមពិនិត្យមើលរាល់ព័ត៌មានដែលលោកអ្នកបានបញ្ចូលឡើងវិញ បន្ទាប់មកសូមធីក "☑ ខ្ញុំបាទ/នាងខ្ញុំ ជានាយកក្រុមហ៊ុន សូមបញ្ជាក់ជាឱឡារិកថាព័ត៌មានដែលបានបំពេញខាងលើគឺពិតជាត្រឹមត្រូវ។ បើព័ត៌មានដែលបានផ្តល់ជូននេះក្លែងក្លាយ ឬខុសពីការពិត ខ្ញុំបាទ/នាងខ្ញុំ សូមទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន។" បន្ទាប់មកចុចប៊ូតុង "បញ្ជាក់ និងទៅជំហានបន្ទាប់"។



❖ **ជំហានទី៤៖** នៅត្រង់ "ជំហានទី៤ ប្រព័ន្ធនឹងបង្កើតវិក្កយបត្របង់ប្រាក់ជូនលោកអ្នកដោយស្វ័យប្រវត្តិ។ ដើម្បីបង់ប្រាក់ និងដាក់ស្នើបាន ប្រព័ន្ធបានបែងចែកជា ២ ជម្រើសគឺ "បង់ប្រាក់តាមរយៈ E-Payment" និង "បង់ប្រាក់តាមវិធីសាស្ត្រផ្សេងទៀត"។




**ករណីបង់ប្រាក់តាម** E-Payment ÷ នៅត្រង់ Tab ទី១ "បង់ប្រាក់តាមរយៈ E-Payment" សូមចុចប៊ូតុង "បង់ប្រាក់ និងដាក់ស្នើ"។




រូបភាព៖ បង់ប្រាក់តាមរយៈ E-Payment

ប្រព័ន្ធនឹងបង្ហាញផ្ទាំងបង់ប្រាក់ដូចរូបខាងក្រោម៖ សូមបញ្ចូល គណនីអេស៊ីលីដា របស់លោកអ្នក បន្ទាប់មកចុចប៊ូតុង "Pay Now" ដើម្បីបង់ប្រាក់។ បន្ទាប់ពីបានបង់ប្រាក់រួចរាល់ ពាក្យស្នើសុំរបស់លោកអ្នកនឹងត្រូវបានដាក់ស្នើដោយស្វ័យប្រវត្តិ ហើយប្រព័ន្ធនឹងបង្កើតបង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ជូនលោកអ្នកផងដែរ។







❖ **ជំហានទី៥៖** នៅពេលពាក្យស្នើសុំរបស់លោកអ្នកត្រូវបានដាក់ស្នើរួចរាល់ មន្ត្រីជំនាញរបស់ **ន.គ.ស.** នឹងពិនិត្យពាក្យស្នើសុំរបស់លោកអ្នក។ ករណីព័ត៌មាន និងឯកសារភ្ជាប់របស់លោកអ្នកត្រឹមត្រូវ **ន.គ.ស.** និងចេញអាជ្ញាបណ្ណជូន។ ករណីដែលព័ត៌មានមិនត្រឹមត្រូវ មន្ត្រីជំនាញ នឹងបញ្ជូនពាក្យស្នើសុំរបស់លោកអ្នកត្រលប់ទៅវិញដើម្បីឱ្យលោកអ្នកកែសម្រួល និងបញ្ជូនឡើងវិញ។

**ករណីបង់ប្រាក់តាមជម្រើសទី២៖** នៅត្រង់ Tab ទី២ "បញ្ចូលបង្កាន់ដៃបញ្ជាក់ការបង់ប្រាក់" សូមបញ្ចូលលេខប្រតិបត្តិការ និងបញ្ចូលបង្កាន់ដៃបញ្ជាក់ការបង់ប្រាក់របស់លោកអ្នក រួចសូមចុចប៊ូតុង "បញ្ចូលបង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ និងដាក់ស្នើ" រួចប្រព័ន្ធនឹងបង្ហាញថាពាក្យស្នើសុំរបស់លោកអ្នកត្រូវបានដាក់ស្នើ។ សម្រាប់បង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពី **ន.គ.ស.** នឹងទទួលបាននៅពេលមន្ត្រីជំនាញរបស់ **ន.គ.ស.** បានពិនិត្យត្រឹមត្រូវ និងអនុម័តជូន។







❖ **ជំហានទី៥៖** នៅពេលពាក្យស្នើសុំរបស់លោកអ្នកត្រូវបានដាក់ស្នើរួចរាល់ មន្ត្រីជំនាញរបស់ **ន.គ.ស.** នឹងពិនិត្យពាក្យស្នើសុំរបស់លោកអ្នក។ ករណីព័ត៌មាន និងឯកសារភ្ជាប់របស់លោកអ្នកត្រឹមត្រូវ **ន.គ.ស.** និងចេញអាជ្ញាបណ្ណជូន។ ករណីដែលព័ត៌មានមិនត្រឹមត្រូវ មន្ត្រីជំនាញ នឹងបញ្ជូនពាក្យស្នើសុំរបស់លោកអ្នកត្រលប់ទៅវិញដើម្បីឱ្យលោកអ្នកកែសម្រួល និងបញ្ជូនឡើងវិញ។

## ៤.៣.១.២.ការស្នើសុំអាជ្ញាបណ្ណសម្រាប់រូបវន្តបុគ្គល ជនបរទេស

លោកអ្នកអាចស្នើសុំអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម សម្រាប់រូបវន្តបុគ្គល ជនបរទេស ដោយអនុវត្តតាមជំហានដូចខាងក្រោម៖

❖ **ជំហានដំបូង៖** សូមចុចលើអាជ្ញាបណ្ណ "រូបវន្តបុគ្គល" សម្រាប់ជនបរទេស បន្ទាប់មកជ្រើសរើស ប្រភេទអាជ្ញាបណ្ណដែលលោកអ្នកចង់ស្នើសុំដូចរូបខាងក្រោម៖




❖ **ជំហានទី១៖** សូមចុចលើអាជ្ញាបណ្ណ "រូបវន្តបុគ្គល" បន្ទាប់មកជ្រើសរើស ប្រភេទអាជ្ញាបណ្ណដែលលោកអ្នកចង់ស្នើសុំដូចរូបខាងក្រោម៖




❖ សូមបន្តជំហានស្រដៀងខាងលើ រហូតដល់ជំហ៊ានចុងក្រោយគឺ "ពាក្យស្នើសុំត្រូវបានដាក់ស្នើ" ។

## ៤.៣.២.ការស្នើសុំអាជ្ញាបណ្ណសម្រាប់នីតិបុគ្គល

លោកអ្នកអាចស្នើសុំអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម សម្រាប់នីតិបុគ្គល ដោយអនុវត្តតាមជំហានដូចខាងក្រោម៖

**ចំណាំ៖** នាយកក្រុមហ៊ុនដែលត្រូវស្នើសុំអាជ្ញាបណ្ណសម្រាប់នីតិបុគ្គល ត្រូវស្នើសុំអាជ្ញាបណ្ណសម្រាប់រូបវន្តបុគ្គលជាមុនសិន។

- **ជំហានដំបូង៖** សូមចុចលើអាជ្ញាបណ្ណ "នីតិបុគ្គល" បន្ទាប់មកជ្រើសរើសប្រភេទអាជ្ញាបណ្ណដែលលោកអ្នកចង់ស្នើសុំដូចរូបខាងក្រោម៖




- **ជំហានទី១៖** នៅត្រង់ "ជំហានទី១ សូមជ្រើសរើសនាយកក្រុមហ៊ុន និងបំពេញព័ត៌មានក្រុមហ៊ុនរបស់លោកអ្នក រួចចុចប៊ូតុង "រក្សាទុក និងទៅជំហានបន្ទាប់"។ ករណីលោកអ្នកមិនទាន់បំពេញរួចរាល់ លោកអ្នកអាចចុចប៊ូតុង "រក្សាទុកបណ្ដោះអាសន្ន" បាន។



សម្រាប់ការបញ្ចូលព័ត៌មានរបស់ក្រុមហ៊ុន ប្រសិនបើក្រុមហ៊ុនរបស់លោកអ្នកបានចុះបញ្ជីពាណិជ្ជកម្មតាមរយៈគណនី CamDigiKey របស់លោកអ្នក នោះព័ត៌មានមួយចំនួនលោកអ្នកពុំចាំបាច់បញ្ចូលទេ ដោយគ្រាន់តែវាយបញ្ចូលលេខចុះបញ្ជីពាណិជ្ជកម្មរបស់លោកអ្នករួចចុចប៊ូតុងធីក(✓)ដូចរូបខាងក្រោម នោះព័ត៌មានរបស់លោកអ្នកនឹងត្រូវបានទាញមកដោយស្វ័យប្រវត្តិ។



❖ **ជំហានទី២៖** នៅត្រង់ "ជំហានទី២ សូមបញ្ចូលឯកសារភ្ជាប់ ដោយចុចប៊ូតុង "បញ្ចូលឯកសារ..." រួចចុច "រក្សាទុក និងទៅជំហានបន្ទាប់"។



❖ **ជំហានទី៣៖** នៅត្រង់ "ជំហានទី៣ សូមពិនិត្យមើលរាល់ព័ត៌មានដែលលោកអ្នកបានបញ្ចូលឡើងវិញ បន្ទាប់មកសូមធីក "☑ ខ្ញុំបាទ/នាងខ្ញុំ ជានាយកក្រុមហ៊ុន សូមបញ្ជាក់ជាឱឡារិកថាព័ត៌មានដែលបានបំពេញខាងលើគឺពិតជាត្រឹមត្រូវ។ បើព័ត៌មានដែលបានផ្ដល់ជូននេះក្លែងក្លាយ ឬខុសពីការពិត ខ្ញុំបាទ/នាងខ្ញុំ សូមទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន។" បន្ទាប់មកចុចប៊ូតុង "បញ្ជាក់ និងទៅជំហានបន្ទាប់"។



❖ **ជំហានទី៤៖** នៅត្រង់ "ជំហានទី៤ ប្រព័ន្ធនឹងបង្កើតវិក្កយបត្របង់ប្រាក់ជូនលោកអ្នកដោយស្វ័យប្រវត្តិ។ ដើម្បីបង់ប្រាក់ និងដាក់ស្នើបាន ប្រព័ន្ធបានបែងចែកជា ២ ជម្រើសគឺ "បង់ប្រាក់តាមរយៈ E-Payment" និង "បង់ប្រាក់តាមវិធីសាស្ត្រផ្សេងទៀត"។




**ករណីបង់ប្រាក់តាម** E-Payment ៖ នៅត្រង់ Tab ទី១ "បង់ប្រាក់តាមរយៈ E-Payment" សូមចុចប៊ូតុង "បង់ប្រាក់ និងដាក់ស្នើ" ។



ប្រព័ន្ធនឹងបង្ហាញផ្ទាំងបង់ប្រាក់ដូចរូបខាងក្រោម។ សូមបញ្ចូល គណនីអេស៊ីលីដា របស់លោកអ្នក បន្ទាប់មកចុចប៊ូតុង “Pay Now” ដើម្បីបង់ប្រាក់។ បន្ទាប់ពីបានបង់ប្រាក់រួចរាល់  ពាក្យស្នើសុំរបស់លោកអ្នកនឹងត្រូវបានដាក់ស្នើដោយស្វ័យប្រវត្តិ ហើយប្រព័ន្ធនឹងបង្កើតបង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ជូនលោកអ្នកផងដែរ។






**ករណីបង់ប្រាក់តាមជម្រើសទី២ ៖** នៅត្រង់ Tab ទី២ "បញ្ចូលបង្កាន់ដៃបញ្ជាក់ការបង់ប្រាក់" សូមបញ្ចូលលេខប្រតិបត្តិការ និងបញ្ចូលបង្កាន់ដៃបញ្ជាក់ការបង់ប្រាក់របស់លោកអ្នក រួចសូមចុចប៊ូតុង "បញ្ចូលបង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ និងដាក់ស្នើ" រួចប្រព័ន្ធនឹងបង្ហាញថាពាក្យស្នើសុំរបស់លោកអ្នកត្រូវបានដាក់ស្នើ។ សម្រាប់បង្កាន់ដៃបញ្ជាក់ការការបង់ប្រាក់ពី **ន.គ.ស.** នឹងទទួលបាននៅពេលមន្ត្រីជំនាញរបស់ **ន.គ.ស.** បានពិនិត្យត្រឹមត្រូវ និងអនុម័តជូន។







❖ **ជំហានទី៥៖** នៅពេលពាក្យស្នើសុំរបស់លោកអ្នកត្រូវបានដាក់ស្នើរួចរាល់ មន្ត្រីជំនាញរបស់ **ន.គ.ស.** នឹងពិនិត្យពាក្យស្នើសុំរបស់លោកអ្នក។ ករណីព័ត៌មាន និងឯកសារភ្ជាប់របស់លោកអ្នកត្រឹមត្រូវ **ន.គ.ស.** និងចេញអាជ្ញាបណ្ណជូន។ ករណីដែលព័ត៌មានមិនត្រឹមត្រូវ មន្ត្រីជំនាញនឹងបញ្ជូនពាក្យស្នើសុំរបស់លោកអ្នកត្រលប់ទៅវិញដើម្បីឱ្យលោកអ្នកកែសម្រួល និងបញ្ជូនឡើងវិញ។

## ៤.៣.៣.ការបង់កម្រៃអាជ្ញាបណ្ណប្រចាំឆ្នាំ

លោកអ្នកអាចបង់កម្រៃអាជ្ញាបណ្ណប្រចាំឆ្នាំជូននិយ័តករគណនេយ្យនិងសវនកម្ម ដោយអនុវត្តតាមជំហានដូចខាងក្រោម៖

❖ **ជំហានទី១៖** សូមចុចលើ "និមិត្តសញ្ញាបង់ប្រាក់" តាមឈ្មោះរូបវន្តបុគ្គល និងតាមប្រភេទអាជ្ញាបណ្ណដែលលោកអ្នកចង់បង់កម្រៃអាជ្ញាបណ្ណប្រចាំឆ្នាំ ដូចរូបខាងក្រោម៖




❖ **ជំហានទី២៖** សូមចុចលើ "បង់ប្រាក់តាមរយៈ E-Payment" បន្ទាប់មកជ្រើសរើសមធ្យោបាយបង់ប្រាក់ "ACLEDA BANK" បន្ទាប់មកទៀតចុចពាក្យ "បង់ប្រាក់"ដូចរូបខាងក្រោម៖



❖ **ជំហានទី៣៖** ក្រោយពេលលោកអ្នកបង់ប្រាក់បានជោគជ័យ ប្រព័ន្ធបង្ហាញថា "បង់ប្រាក់ជោគជ័យ" បន្ទាប់មក លោកអ្នកចុចពាក្យ "ត្រលប់ក្រោយ" ដើម្បីទៅកាន់ទំព័រដើមវិញ ដូចរូបខាងក្រោម៖



## ៤.៣.៤.ការបន្តសុពលភាពអាជ្ញាបណ្ណ

លោកអ្នកស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណបាន ដោយអនុវត្តដូចខាងក្រោម៖

❖ **ជំហានទី១៖** សូមចុចលើ "បន្តសុពលភាព" ដើម្បីមើលព័ត៌មានក្នុងតារាងជាមុន រួចចុចលើ "បន្តសុពលភាពអាជ្ញាបណ្ណ"



❖ **ជំហានទី២៖** សូមជ្រើសរើសអាជ្ញាបណ្ណ "បង្ហាញ ឈ្មោះនិងប្រភេទអាជ្ញាបណ្ណ" រួចចុចពាក្យ "បន្ទាប់"



❖ សូមបន្តជំហានស្រដៀងខាងលើ រហូតដល់ជំហ៊ានចុងក្រោយគឺ "ពាក្យស្នើសុំត្រូវបានដាក់ស្នើ" ។

# ៥. ផ្នែកទំនាក់ទំនង




## ❖ ទំនាក់ទំនងតាម Telegram ដូចខាងក្រោម៖

### ផ្នែកផ្តល់អាជ្ញាបណ្ណ

- លោកស្រី នេត្រ រតនា ០៦៩ ៥៩៦ ២៥៥
  *អនុប្រធានការិយាល័យ*
- លោកស្រី មូល ផល្លា ០៦១ ៦៩៩ ៤៦៤
  *អនុប្រធានការិយាល័យ*
- លោកស្រី ទឹម ដានិត ០៩៦ ៣៣ ៦៦ ៣៤៣
  *អនុប្រធានការិយាល័យ*

### ផ្នែកព័ត៌មានវិទ្យា

- លោក យន់ ស៊ីវត្ថា ០១៥ ២៨៦ ១២០
  *អនុប្រធានការិយាល័យ*